ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ: ១៨ អយក.សាជំណ

## សេចក្តីជូនដំណឹង

## ស្តីពីការប្រឡងជ្រើសរើសនិស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និង ថ្នាក់បរិញ្ញាបត្រទៅសិក្សានៅសាធារណរដ្ឋប្រជាមានិតចិនក្នុងឆ្នាំសិក្សា២០១២-២០១៣

**យោង**: លិខិតលេខ(2011)No.374 ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ របស់ស្ថានទូតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា

**ក្រសួងអប់រំ យុវជន និងកីឡា**

សូមជូនដំណឹងថា ក្នុងឆ្នាំ២០១២នេះរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនបានផ្តល់អាហារូបករណ៍ចំនួន៥១កន្លែងដល់សិស្ស-និស្សិត-មន្ត្រីរាជការ-បុគ្គលិកអង្គការ-ក្រុមហ៊ុននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទៅបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បរិញ្ញាបត្រនៅសាធារណរដ្ឋប្រជាមានិតចិនសម្រាប់ឆ្នាំសិក្សា២០១២-២០១៣ ។ សោហ៊ុយធ្វើដំណើរទៅ-មកជាបន្ទុករបស់សាមីជន ឯការចំណាយផ្សេងៗលើការស្នាក់នៅ ការសិក្សា និងប្រាក់អាហារូបករណ៍ជាបន្ទុករបស់រដ្ឋាភិបាលចិន ។

**I-មុខវិជ្ជាសម្រាប់សិក្សាមាន**:

-វិទ្យាសាស្ត្រ វិស្វកម្ម សេដ្ឋកិច្ច ការគ្រប់គ្រងពាណិជ្ជកម្ម វេជ្ជសាស្ត្រ ព័ត៌មានវិទ្យា ។ល។

**II-លក្ខខណ្ឌនៃការដាក់ពាក្យ**

ក/ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

បេក្ខជនទាំងពីរភេទត្រូវ:

-មានសញ្ជាតិខ្មែរ

-មានសញ្ញាបត្របរិញ្ញាបត្រ (Bachelor)

-មានអាយុយ៉ាងច្រើន ៣៥ ឆ្នាំ

-មានចំណេះដឹងភាសាអង់គ្លេសជ្រៅជ្រះព្រោះការសិក្សាប្រព្រឹត្តទៅជាភាសាអង់គ្លេស

-មានសុខភាពល្អបរិបូណ៌ទាំងកាយសម្បទា និងសតិបញ្ញា

អាស័យដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: ( ៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
Email: crsmeys@camnet.com.kh Web Site: www.moeys.gov.kh

ឧ/ថ្នាក់បរិញ្ញាបត្រ

បេក្ខជនទាំងពីរភេទត្រូវ:

-មានសញ្ជាតិខ្មែរ

-មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ

-មានអាយុមិនលើសពី២៥ ឆ្នាំ

-មានសុខភាពល្អបរិបូណ៌ទាំងកាយសម្បទា និងសតិបញ្ញា

III-**កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យ**

ពាក្យសុំប្រឡងនឹងត្រូវបានទទួលចាប់ពីថ្ងៃផ្សាយដំណឹងនេះរហូតដល់ថ្ងៃទី ១០ ខែកុម្ភៈឆ្នាំ២០១២វេលាម៉ោង ១៦ម៉០០ នៅការិយាល័យអាហារូបករណ៍ និងកម្មសិក្សានៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ដែលមានអាស័យដ្ឋានអគារលេខ ២៣ ផ្លូវ ៣៦០ សង្កាត់បឹងកេងកង១ ខ័ណ្ឌចំការមន(ខាងកើតស្ថានីយ៍ទូរទស្សន៍អប្សរា ប្រហែល៥០ម៉ែត្រ) ។

IV-**កាលបរិច្ឆេទប្រឡង**

ប្រឡងនៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ។ មណ្ឌលប្រឡងនឹងជម្រាបជូនពេលក្រោយ ។

V-**វិញ្ញាសាប្រឡង**

*សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់*

-វប្បធម៌ទូទៅ រយៈពេល ០១ម៉ោង ៣០នាទី

-ភាសាអង់គ្លេស រយៈពេល ០១ម៉ោង ៣០នាទី

*សម្រាប់ថ្នាក់បរិញ្ញាបត្រ*

-គណិតវិទ្យា រយៈពេល ០១ម៉ោង ៣០នាទី

-ភាសាអង់គ្លេស រយៈពេល ០១ម៉ោង ៣០នាទី

VI-**សំណុំឯកសារត្រូវបំពេញ និងភ្ជាប់មកជាមួយមាន:**

| | | |
|---|---|---|
| ១-បង្កាន់ដៃទទួលពាក្យ | ០១ច្បាប់ | "មានគំរូ" |
| ២-ពាក្យសុំអាហារូបករណ៍ | ០១ច្បាប់ | "មានគំរូ" |
| ៣-ជីវប្រវត្តិសង្ខេប | ០១ច្បាប់ | "មានគំរូ" |
| ៤-កិច្ចសន្យា | ០១ច្បាប់ | "មានគំរូ" |
| ៥-រូបថត ៤ គុណ ៦ | ០៤សន្លឹក | (ពណ៌ធម្មជាតិទើបថតថ្មី) |

៦-សញ្ញាបត្របរិញ្ញាបត្រ(ច្បាប់ថតចម្លង ០១ ច្បាប់) សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

៧-សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ (ច្បាប់ថតចម្លង ០១ច្បាប់)សូមភ្ជាប់ ច្បាប់ដើមមកជាមួយដើម្បីផ្ទៀងផ្ទាត់សម្រាប់ថ្នាក់បរិញ្ញាបត្រ ។

៨-លិខិតបញ្ជាក់ការសិក្សាពីគ្រឹះស្ថានសិក្សាចំពោះនិស្សិតកំពុងសិក្សាតាមគ្រឹះស្ថានឧត្តមសិក្សានានា។

៩-លិខិតឧទ្ទេសនាមពីថ្នាក់ក្រសួង ៉ចំពោះបេក្ខជន ជាមន្ត្រីរាជការ៉

១០-វិញ្ញាបនបត្រពិនិត្យកាយសម្បទា ៉០២សន្លឹក៉ បំពេញក្រោយពេលដែលសាមីជនត្រូវបាន ជ្រើសរើសរួច។

ផ្អែកលើលទ្ធផលប្រឡងក្រសួងអប់រំ យុវជន និងកីឡានឹងជ្រើសរើសនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ២០នាក់ និងថ្នាក់បរិញ្ញាបត្រចំនួន៨៥នាក់ ដើម្បីបញ្ជូនទៅស្ថានទូតចិនធ្វើតេស្ត និងសម្ភាសន៍ជាបន្តបន្ទាប់ទៀត ។

ចំពោះព័ត៌មានលម្អិតបន្ថែមទៀតសូមអញ្ជើញទាក់ទងជាមួយការិយាល័យអាហារូបករណ៍ និងកម្មសិក្សាតាមអាស័យដ្ឋានខាងលើ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០១២

ត.ប រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

អគ្គនាយក

ថោង បូរ៉ាន់

**<u>កន្លែងទទួល</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ក្រសួងមហាផ្ទៃ

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ស្ថានទូតសាធារណរដ្ឋប្រជាមានិតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា

៉ដើម្បីជូនជ្រាបជាព័ត៌មាន៉

-គ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-គ្រប់គ្រឹះស្ថានឧត្តមសិក្សា

-គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត-ក្រុង

៉ដើម្បីជួយផ្សព្វផ្សាយ និងឧទ្ទេសនាម៉

-កាលប្បវត្តិ ឯកសារ នា.ទវអ